ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ.១១២២៩....អពដ

# សូមគោរពជូន

## ឯកឧត្តមបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិកពេញសិទ្ធិនៃរាជបណ្ឌិត្យសភាកម្ពុជា

តាងនាមថ្នាក់ដឹកនាំ មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃអគ្គនាយកដ្ឋានពន្ធដារ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមអនុញ្ញាតសម្តែងនូវអំណរសាទរយ៉ាងស្មោះអស់ពីដួងចិត្ត ប្រកបដោយសេចក្តីសោមនស្សរីករាយ ជូនចំពោះ**ឯកឧត្តមបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងឱកាសដែលឯកឧត្តមត្រូវបាន**ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** តែងតាំងជាសមាជិកពេញសិទ្ធិនៃរាជបណ្ឌិត្យសភាកម្ពុជា មានគោរមងារជា **បណ្ឌិតសភាចារ្យ**។

ឯកឧត្តមបណ្ឌិតសភាចារ្យ គឺជាធនធានដ៏កម្រសម្រាប់សង្គមជាតិ ជាធនធានមនុស្សប្រកបដោយគុណវុឌ្ឍិខ្ពស់ ពោរពេញដោយសមត្ថភាព និងពុទ្ធិដ៏ឧត្តុង្គឧត្តម ទាំងនៅលើវិស័យវិទ្យាសាស្ត្រនយោបាយ សេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងវិស័យផ្សេងៗទៀតជាច្រើន។ ឯកឧត្តមបណ្ឌិតសភាចារ្យ បាននិងកំពុងយកអស់កម្លាំងកាយចិត្ត ប្រាជ្ញាស្មារតី បម្រើជាតិមាតុភូមិ ដោយមិនគិតពីការនឿយហត់និងពេលវេលាផ្ទាល់ខ្លួន ក្នុងការរួមចំណែកយ៉ាងសំខាន់ជាមួយរាជរដ្ឋាភិបាលក្រោមការដឹកនាំ ដ៏ខ្ពង់ខ្ពស់ប្រកបដោយបញ្ញាញាណឈ្លាសវៃរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** រហូតទទួលបានកំណើនសេដ្ឋកិច្ចគួរជាទីមោទនៈ។

ក្នុងឱកាសដ៏មហាឧត្តុង្គឧត្តម ប្រសើរថ្លៃថ្លា ប្រកបដោយមោទនភាពជាតិដ៏ក្រលែងនេះ ខ្ញុំសូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោក ទេវតាថែរក្សាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា គុណបុណ្យព្រះរតនត្រ័យកែវទាំងបី ទេវតាថែរក្សាឆ្នាំថ្មី សូមព្រះអង្គតាមជួយអភិបាលរក្សា ប្រោសព្រំសព្ទសាធុការពរជ័យគ្រប់ប្រការ ចំពោះ**ឯកឧត្តមបណ្ឌិតសភាចារ្យ** សូមសមប្រកបនឹងសុខភាពល្អបរិបូណ៌ ពលានុភាពមាំមួន ប្រាជ្ញាញាណភ្លឺថ្លា ជន្មាយុយឺនយូរ និងសូមទទួលបាននូវជោគជ័យថ្មីៗធំធេងថែមទៀត ក្នុងការអភិវឌ្ឍវិស័យសេដ្ឋកិច្ចជាតិ។

ជាថ្មីម្តងទៀត តាងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការពន្ធដារគ្រប់លំដាប់ថ្នាក់ ខ្ញុំសូមប្តេជ្ញាចិត្តខ្ពស់ក្នុងការអនុវត្តប្រកបដោយជោគជ័យ នូវមាគ៌ានយោបាយដឹកនាំរបស់ឯកឧត្តមបណ្ឌិតសភាចារ្យ ទេសរដ្ឋមន្ត្រី និងសូមបួងសួងដល់ទេព្តាឆ្នាំថ្មី សូមប្រសិទ្ធពរបវរមហាប្រសើរ ជូនចំពោះ**ឯកឧត្តមបណ្ឌិតសភាចារ្យ និងលោកជំទាវ** សូមសមប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តមបណ្ឌិតសភាចារ្យ ទេសរដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ ពីខ្ញុំ

គោរពជូនពរ និងអបអរសាទរ នៅរាជធានីភ្នំពេញ, ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៧

**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**